## តើខ្ញុំអាចទទួលបានពត៌មានបន្ថែមទៀតស្តីអំពី ASPEC នៅទីណា?

ពត៌មានបន្ថែមដែលលោកអ្នកចង់បាននោះ គឺលោកអ្នកអាចរកបានតាមនិវេទន៍ និងតាមរយ:គេហទំព័រ របស់ការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ាននីមួយៗ ឬអាចចូលបានតាមរយ: គេហទំព័ររបស់កម្មសិទ្ធិបញ្ញាអាស៊ាន (http://www.aseanip.org)

| ការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានដែលបានចូលរួម | អសយដ្ឋានគេហទំព័ររបស់ការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានដែលបានចូលរួម | លេខទំនាក់ទំនងរបស់សមាជិក ASPEC |
|---|---|---|
| ប្រ៊ុយណេ | http://www.brunei-patents.com.bn/ | +673 223 0111 ext 170 |
| កម្ពុជា | http://www.cambodiaip.gov.kh/ | +855 23 218 030 |
| ឥណ្ឌូនេស៊ី | http://www.dgip.go.id/ | +62 21 5790 5606 |
| ឡាវ | http://www.aseanip.org/ | +856 21 240784 |
| ម៉ាឡេស៊ី | http://www.myipo.gov.my/ | +603 2299 8814 |
| ហ្វីលីពីន | http://www.ipophil.gov.ph/ | +632 238 6300 loc.407 |
| សិង្ហបុរី | http://www.ipos.gov.sg/ | +65 6330 8612 |
| ថៃឡង់ដ៍ | http://www.ipthailand.go.th/ | +66 25474716 |
| វៀតណាម | http://www.noip.gov.vn/ | +84 4 3858 5223 |

The Association of Southeast Asian Nations (ASEAN) was established on 8 August 1967. The Member States of the Association are Brunei Darussalam, Cambodia, Indonesia, Lao PDR, Malaysia, Myanmar, Philippines, Singapore, Thailand and Viet Nam. The ASEAN Secretariat is based in Jakarta, Indonesia.

For inquiries, contact: The ASEAN Secretariat, Public Outreach and Civil Society Division I 70A Jalan Sisingamangaraja, Jakarta 12110, Indonesia
Phone : (62 21) 724-3372, 726-2991 I Fax : (62 21) 739-8234, 724-3504 I E-mail : public@asean.org

General information on ASEAN appears online at the ASEAN Website: www.asean.org

Catalogue-in-Publication Data: ASEAN Patent Examination Cooperation (ASPEC) (Khmer) I Jakarta: ASEAN Secretariat, August 2014
352.749 I 1. ASEAN – Intellectual Property - Patent I 2. Public Administration – IP Offices I ISBN 978-602-7643-78-9

Photo credits: Intellectual Property Office of Singapore

The text of this publication may be freely quoted or reprinted, provided proper acknowledgement is given and a copy containing the reprinted material is sent to Public Outreach and Civil Society Division of the ASEAN Secretariat, Jakarta.

Copyright Association of Southeast Asian Nations (ASEAN) 2014. All rights reserved.

ASEAN @ASEAN

# សហប្រតិបត្តិការនៃការពិនិត្យប្រកាសនីយបត្រតក្កកម្មអាស៊ាន (ASPEC)

## ការចារួមគ្នាថ្នាក់តំបន់ដំបូង ដែលបានចូលរួមដោយការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ាន

INTELLECTUAL PROPERTY OFFICE BRUNEI DARUSSALAM



IPOS INTELLECTUAL PROPERTY OFFICE OF SINGAPORE

one vision
one identity
one community

# កម្មវិធីរបស់ ASPEC

### តើ ASPEC ជាអ្វី?

សហប្រតិបត្តិការនៃការពិនិត្យប្រកាសនីយបត្រតក្កកម្មអាស៊ាន (ASPEC) គឺជាកម្មវិធីការងាររួមគ្នាផ្នែកប្រកាសនីយបត្រតក្កកម្មថ្នាក់តំបន់ជាលើកដំបូងដែលសមាជិកការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានចូលរួមមានចំនួន ៩ ប្រទេស គឺ: ប្រ៊ុយណេ កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃឡង់ដ៍ និងវៀតណាម ។ អ្នកដាក់ពាក្យសុំទាំងឡាយ នឹងអាចមានលទ្ធភាពទទួលបាននូវផលប្រយោជន៍ក្នុងការដំណើរការបន្តយ៉ាងរហ័សការិយាល័យកម្មសិទ្ធិបញ្ញាដែលបានចូលរួមជាសមាជិក ASPEC ចាប់ពីពេលដាក់ពាក្យស្នើសុំរហូតដល់ ពេលទទួលបានប្រកាសនីយបត្រតក្កកម្ម ។

**"អ្នកដាក់ពាក្យសុំទាំងឡាយ ដែលមានបំណងចង់ដាក់ពាក្យស្នើសុំថ្នាក់តំបន់ក្នុងបណ្តាប្រទេសសមាជិកអាស៊ាន នឹងទទួលបានអត្ថ ប្រយោជន៍ ពី ASPEC ដោយអាចសន្សំសំចៃតម្លៃ និងពេលវេលា"**



### អត្ថប្រយោជន៍នៃការប្រើប្រាស់ ASPEC

គោលបំណងទាំងឡាយនៃការប្រើប្រាស់ ASPEC គឺដើម្បីកាត់បន្ថយភាពស្មុគស្មាញ សន្សំសំចៃពេលវេលាបានច្រើន និងធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការពិនិត្យ និង ស្រាវជ្រាវ ។ យោងតាមការងារដែលបានអនុវត្តកន្លងមក ដោយការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានដទៃទៀត វាអាចជួយដល់អ្នកពិនិត្យប្រកាសនីយបត្រតក្កកម្មក្នុងការអភិវឌ្ឍន៍លក្ខណៈវិនិច្ឆ័យនៃការស្រាវជ្រាវ ឬយុទ្ធសាស្ត្ររបស់ខ្លួនឲ្យបានកាន់តែលឿន កាត់បន្ថយការស្រាវជ្រាវ និងឬជួយដល់អ្នកពិនិត្យប្រកាសនីយបត្រតក្កកម្ម ដើម្បីឲ្យយល់ពីតក្កកម្មដែលបានអះ អាងការពារបានកាន់តែលឿន ។ ការិយាល័យកម្ម សិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានមួយ ក៏អាចចូលទៅរកទិន្នន័យទាំងឡាយដែលមិនអាចរកបាននៅក្នុងការិយាល័យកម្មសិទ្ធិ បញ្ញានៃប្រទេសសមាជិកអាស៊ានដទៃទៀត ផងដែរ ហើយហេតុនេះ ហើយវាអាចផ្តល់ ឱកាសដោយយោងទៅលើលទ្ធផលទាំងឡាយនៃការស្រាវជ្រាវ និងពិនិត្យ ដែលអាចផ្តល់ដល់អ្នកពិនិត្យនូវព័ត៌មានស្តីពី និងការប៉ាន់ប្រមាណនៃស្នាដៃមុនៗដោយគាត់មិនអាចចូលទៅរកបានកាលពីមុន។

ASPEC ប្រតិបត្តិការជា ភាសាអង់គ្លេស ដល់គ្រប់ការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសដែលចូលរួមជាសមាជិកអាស៊ាន ។ ការបកប្រែភាសាអង់គ្លេសសម្រាប់ឯកសារទាំងឡាយដែលបានផ្តល់ មិនចាំបាច់បញ្ជាក់ដោយអ្នកបកប្រែ ឬដោយភ្នាក់ងារ ណាឡើយ លុះត្រាតែមានការស្នើសុំពីការិយាល័យនោះ ។ ដំណើរការបន្ត នៅការិយាល័យកម្មសិទ្ធិ បញ្ញានៃប្រទេសសមាជិកអាស៊ាន នឹងត្រូវបានពន្លឿនទៅមុខរហូតដល់ពេលផ្តល់ប្រកាសនីយបត្រតក្កកម្មនៅពេលមានការស្នើសុំ ។ ហេតុដូច្នេះ អ្នកដាក់ពាក្យទាំងអស់មានបំណងដាក់ពាក្យសុំក្នុងប្រទេសសមាជិកអាស៊ាន នឹងទទួលបានប្រយោជន៍ពី ASPEC ដោយសារតែអាចសន្សំសំចៃថវិកា និងពេលវេលាបាន យ៉ាងច្រើន។



### តើខ្ញុំទទួលបានគុណសម្បត្តិអ្វីខ្លះចំពោះការដាក់ពាក្យស្នើសុំតាមរយៈ ASPEC?

ការដាក់ពាក្យតាម ASPEC អាចត្រូវបានដាក់ នៅគ្រប់ការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេស សមាជិកអាស៊ាន ។ លោកអ្នកនឹងទទួលបាននូវលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការ ដាក់ពាក្យនេះ ប្រសិនបើ (i) ការដាក់សំណុំលិខិតស្នើសុំប្រកាសនីយបត្រចំពោះតក្កកម្មដែលដូចគ្នានៅការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ាន ហើយសំណុំលិខិតស្នើសុំទាំងនោះមានទំនាក់ទំនងទៅនឹងការអះអាងសិទ្ធិអាទិភាពនៃសន្ធិសញ្ញាទីក្រុងប៉ារីស (Paris Convention) និង (ii) លោកអ្នកមានឯកសារពិនិត្យ និងស្រាវជ្រាវ ដែលចេញដោយការិយាល័យណាមួយនៃការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ាន ដែលបាន ចូលរួមជាសមាជិក ដែលយ៉ាងហោចណាស់ក៏មានសេចក្តីអះអាងដែលបានកំណត់ត្រូវបាន អនុញ្ញាតឲ្យ ឬទទួលបាននូវប្រកាសនីយបត្រតក្កកម្ម ។

### តើការប្រើប្រាស់ ASPEC មានការបង់ថ្លៃឬទេ?

ចំពោះអ្នកពាក្យស្នើសុំនៅការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានដែលបាន ចូលរួមជាសមាជិក ASPEC គឺគ្មានការបង់ថ្លៃនោះទេ ។ ប៉ុន្តែទោះជាយ៉ាងក៏ដោយ តម្លៃ សម្រាប់ការស្រាវជ្រាវ និងពិនិត្យនៅការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ាន ត្រូវតែបង់។

### តើខ្ញុំអាចដាក់សំណុំលិខិតស្នើសុំទៅ ASPEC នៅពេលណា?

ASPEC អាចដាក់ស្នើសុំបាននៅគ្រប់ពេល មុនពេលផ្តល់ ឬបដិសេធផ្តល់ប្រកាសនីយបត្រ តក្កកម្ម ។

### តើខ្ញុំត្រូវដាក់ពាក្យស្នើសុំ ASPEC ដូចម្តេច?

ជាទូទៅ ដើម្បីស្នើសុំដាក់ ASPEC អ្នកដាក់ពាក្យស្នើសុំត្រូវដាក់បានយ៉ាងងាយស្រួល ដោយត្រូវបំពេញទម្រង់គំរូ ASPEC (ដែលអាចរកបានតាមរយៈគេហទំព័ររបស់ការិយាល័យ កម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានដែលមានអមជាមួយដោយឯកសារពិនិត្យ និងស្រាវជ្រាវដែលឆ្លើយតបទៅនឹងសំណុំលិខិតស្នើសុំសម្រាប់តក្កកម្មដែលដូចគ្នាដែលចេញដោយការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសមាជិកអាស៊ានដែលជាសមាជិក ASPEC ណាមួយ និងឯកសារថតចម្លងនូវសេចក្តីអះអាងទាំងឡាយយោងទៅក្នុងរបាយការណ៍ ដែលបានផ្តល់ជូននោះ។